ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 12 / 09 / 2013
ម៉ោង (Time/Heure) : 10.00 AM
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier:

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១៣

ជូនចំពោះ៖ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

ពី៖ ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

ចម្លងជូន៖ លោក/លោកស្រីចៅក្រម និងមន្ត្រីច្បាប់ជាន់ខ្ពស់ នៃអង្គជំនុំជម្រះសាលាដំបូង ភាគីទាំងអស់នៃសំណុំរឿង ០០២ និង ផ្នែកគាំពារជនរងគ្រោះ

កម្មវត្ថុ៖ សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំពន្យាពេលដាក់សារណាចុងក្រោយស្តីពីសំណង

១. នៅថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០១៣ អង្គជំនុំជម្រះបានកំណត់ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ ជាកាលបរិច្ឆេទចុងក្រោយសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីដាក់សារណាចុងក្រោយស្តីពីសំណង (E218/7/2)។ នៅថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០១៣ អង្គជំនុំជម្រះបានស្នើព័ត៌មានបន្ថែមទាក់ទងនឹងគម្រោងសំណងជាក់លាក់មួយចំនួនដែលបានស្នើឡើងដោយដើមបណ្តឹងរដ្ឋប្បវេណី ហើយបានបញ្ជាក់ថា កាលបរិច្ឆេទចុងក្រោយសម្រាប់ដាក់សារណាចុងក្រោយស្តីពីសំណង គឺនៅត្រឹមថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ (E218/7/4) ។ ឥឡូវ សហមេធាវីនាំមុខអន្តរជាតិតំណាងដើមបណ្តឹង រដ្ឋប្បវេណី តាមរយៈអ៊ីម៉ែល នៅថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ២០១៣ បានស្នើសុំពន្យាពេលពីរសប្តាហ៍សម្រាប់ការដាក់សារណាចុងក្រោយស្តីពីសំណង ដើម្បីមានពេលវេលាសម្រាប់រៀបចំការដាក់សារណានេះ បន្ទាប់ពីភាគីនានាដាក់សារណាបិទការពិភាក្សាដេញដោល ដែលត្រូវដាក់ត្រឹមថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ ដែរ។

២. អង្គជំនុំជម្រះសូមរំលឹកថា នៅថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៣ អង្គជំនុំជម្រះបាន

ពន្យាពេលឱ្យភាគីនានាចំនួនមួយសប្តាហ៍សម្រាប់ការដាក់សារណាបិទការពិភាក្សាដេញដោលហើយបាន ពិចារណាឃើញថា វាជាការត្រឹមត្រូវផងដែរក្នុងការពន្យារពេលកាលបរិច្ឆេទកំណត់ដល់ ដើមបណ្តឹងរដ្ឋប្បវេណីដើម្បីដាក់សារណាស្តីពីសំណង។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះកត់សម្គាល់ ថាការពន្យាពេលពីរសប្តាហ៍សម្រាប់កាលបរិច្ឆេទកំណត់ ដូចដែលបានស្នើឡើងដោយដើមបណ្តឹងរដ្ឋប្បវេណីនោះ នឹងមិនអនុញ្ញាតឱ្យអង្គជំនុំជម្រះ និងភាគីដទៃទៀត មានពេលវេលា ដើម្បីពិនិត្យលើការទាមទារសំណងនេះ មុនសវនាការធ្វើសេចក្តី សន្និដ្ឋានបិទការពិភាក្សាដេញដោល ដែលនឹងត្រូវចាប់ផ្តើមធ្វើនៅថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ នោះបានទេ។ ហេតុដូច្នេះ អង្គជំនុំជម្រះបង្គាប់ឱ្យដើមបណ្តឹងរដ្ឋប្បវេណីដាក់សារណាស្តីពីសំណង នៅត្រឹមថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០១៣។